**មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក)**

ផ្ទះលេខ ១១៩ ផ្លូវ ២៥៧ សង្កាត់ទឹកល្អក់ ១ ខ័ណ្ឌទួលគោក រាជធានីភ្នំពេញ

ប្រអប់សំបុត្រលេខ ១១១៨ ទូរស័ព្ទ: ៨៥៥-២៣-៨៨០ ៩១៦ ទូរសារ: ៨៥៥-២៣-៨៨៥ ១៤៦


# សេចក្តីប្រកាសព័ត៌មាន

***Released June 21, 2010***

## សូមណែនាំនូវ របៀបធ្វើស្រែលើដីតូច បានផលចំណោញច្រើន

មជ្ឈមណ្ឌលសិក្សានិងអភិវឌ្ឍន៍កសិកម្មកម្ពុជា (អង្គការសេដាក) ជាអង្គការមិនមែនរដ្ឋាភិបាលខ្មែរ ឯករាជ្យ មិនស្វែងរកកំរៃផលប្រយោជន៍បុគ្គល និងមិនពាក់ព័ន្ធគណបក្សនយោបាយ។ សេដាក បានត្រូវបង្កើតឡើងនៅឆ្នាំ ១៩៩៧ ក្នុងគោលបំណងពង្រឹងសមត្ថភាព និងភាពជាម្ចាស់របស់កសិករ ក្នុងការកែលំអគុណភាពជីវិតរបស់ខ្លួន និងចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍សង្គម”។

ខណៈដែលប្រជាកសិករខ្មែរបាននិងកំពុងតែមមាញឹកជាមួយការធ្វើស្រែនៅរដូវវស្សាឆ្នាំនេះ មជ្ឈមណ្ឌលសិក្សា និងអភិវឌ្ឍន៍កសិកម្មកម្ពុជា (សេដាក) សូមធ្វើការណែនាំនូវ របៀបធ្វើស្រែលើដីតូច បានទទួលផលចំពេញច្រើន ជូនដល់ប្រជាកសិករខ្មែរ។

លោកបណ្ឌិត យ៉ង សាំងកុមារ ប្រធានអង្គការសេដាកមានប្រសាសន៍ថា កសិករគ្រប់រូបអាចទទួលបានទិន្នផលស្រូវខ្ពស់និងផលចំណេញច្រើននៅលើដីស្រែតូចដែលខ្លួនមាន ដោយគ្រាន់តែងាកមកអនុវត្តការធ្វើស្រែតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស)។ លោកបណ្ឌិតបន្តថា ចំនុចសាមញ្ញ ងាយៗចំនួន ១៤ នៃប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវតាមគោលការណ៍ធម្មជាតិ (ប.វ.ស) រួមមាន:

១- រើសតែគ្រាប់ពេញល្អ និងសុទ្ធយកទៅសាប

២- សាបលើថ្នាលគោក ដូចរងស្ពៃ

៣- ដកថ្នមៗ ហើយដកភ្លាម ស្ទូងភ្លាម

៤- ស្ទូងតែសំណាបថ្លោស

៥- ស្ទូងសំណាបអាយុខ្ចី យកល្អតិចជាង ១៥ ថ្ងៃ

៦- ស្ទូងរាក់ដោយគ្រាន់តែផ្តិតឫសជាប់ដី

៧- ស្ទូងចាប់តិច យកល្អចាប់ ១ ដើម ឬ ២ ដើម

៨- ស្ទូងចន្លោះគុម្ពស្មើគ្នា ហើយរាងឆ្ងាយពីគ្នាបន្តិច

៩- ដកស្មៅឱ្យបានទាន់ពេល និងញឹកញាប់

១០-ទុកទឹកតិចៗ ឬក៏គ្រាន់តែដីសើមៗនៅពេលស្ទូង និងនៅពេលស្រូវបែកគុម្ព

១១-ប្រើជីកំប៉ុស្តឱ្យបានច្រើន

១២-ដាំដំណាំជីបៃតងមុនស្ទូង ឬក្រោយពេលច្រូត

១៣-គ្របដីនៅចន្លោះគុម្ពស្រូវ ដោយប្រើកាកសំណល់រុក្ខជាតិផ្សេងៗ

១៤-រើសតែកួរ និងស្មែងល្អៗទុកពូជ ហើយប្រឡះគ្រាប់ពូជនឹងដៃថ្មមៗ

លោកបណ្ឌិតបញ្ជាក់បន្ថែមថា ក្នុងចំណោមចំណុចទាំង ១៤ កសិករអាចអនុវត្តនូវចំណុចណាមួយក៏បានដែរ ប៉ុន្តែលោកបណ្ឌិតបន្ថែមថា ការអនុវត្តបាននូវចំនុចខាងលើកាន់តែច្រើនកាលណា នាំអោយផលរបស់គាត់កាន់តែល្អ និងបានផលចំណេញកាន់តែច្រើនតាមនោះដែរ។ លោកបន្តថា យ៉ាងអន់ណាស់ បើកសិកររើសតែសំណាបថ្លោសទៅស្ទូង ស្ទូងចាប់ ១ដើមឬ ២ដើម ស្ទូងរាក់ ពួកគាត់នឹងអាចទទួលបានផលច្រើនលើសធម្មតាផងដែរ។ "ចំពោះស្រែដែលមានទឹកដក់ច្រើន គួរកុំស្ទូងសំណាបខ្ចីពេក ហើយបើសំណាបចាស់ សូមស្ទូងរាងតៀកគ្នាបន្តិច" លោកបណ្ឌិតបញ្ជាក់បន្ថែម។

តាមបទពិសោធន៏កន្លងមក ការអនុវត្តការធ្វើស្រែតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិ (ប.វ.ស)នេះបានផ្តល់ផលចំណេញជាច្រើនជូនដល់ប្រជាកសិករខ្មែរ ពិសេសគឺការទទួលបានទិន្នផលស្រូវខ្ពស់ពី ៣-៤ តោនក្នុងមួយហិកតា ហើយកាត់បន្ថយនូវទៅលើពូជ ជីគីមី និងថ្នាំពុលគីមី។

គួរបញ្ជាក់ថា របៀបធ្វើស្រែតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិ (ប.វ.ស) ត្រូវបានណែនាំដំបូងនៅប្រទេសកម្ពុជា ដោយអង្គការសេដាក ដោយមានកសិករចាប់ផ្តើមសាកល្បងដំបូងចំនួន ២៨គ្រួសារ។ មកដល់ពេលបច្ចុប្បន្ន កសិករចំនួនជាង ១១ ម៉ឺនគ្រួសារបាននិងកំពុងអនុវត្ត របៀបធ្វើស្រែតាមប្រព័ន្ធប្រពលវប្បកម្មដំណាំស្រូវ តាមគោលការណ៍ធម្មជាតិ (ប.វ.ស) នេះនៅទូទាំងប្រទេសកម្ពុជា។ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបាននិងកំពុងដើរតួរសំខាន់ក្នុងការជំរុញ ប.វ.ស នៅកម្ពុជា។

**ទំនាក់ទំនង:** សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង លោក ហ៊ុម ខទៀត: ០១៦ ៩៧៥ ៧១៣



Centre d'Etude et de Développement Agricole Cambodgien (CEDAC)

No 119 St. 257 Sangkat Teuk Laak 1, Khan Toul Kork, Phnom Penh - Cambodia
P.O.Box: 118, Tel.: 855-23-880 916, Fax: 855-23-885-146, E-mail: cedac@online.com.kh